# ជំពូកទី ៧

## ៧. ការពិគ្រោះយោបល់សាធារណៈ

គោលបំណងនៃការពិគ្រោះយោបល់សាធារណៈ និងការប្រជុំជាមួយអ្នកពាក់ព័ន្ធសំរាប់ការសិក្សា EIA របស់ គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោម ២ គឺដើម្បីផ្សព្វផ្សាយពតិមានគំរោង, ប្រមូលយោបល់ ឬ គំនិតចូលរួមពី អ្នកពាក់ព័ន្ធ ដើម្បីកែលំអការរៀបចំប្លង់គំរោង ការសាងសង់ និង ការអនុវត្តគំរោងអោយបានល្អ។

ការចូលរួម ត្រូវបានបំពេញបង្រ្គប់តាមការសំភាសន៍ដោយឡែកជាមួយនឹងអ្នកពាក់ព័ន្ធជាគោលដៅ ( គ្រួសារ និង ស្ថាប័នពាក់ព័ន្ធ) ពេញកំឡុងពេលសិក្សា EIA ។ នៅក្នុងផ្នែកនេះ មនុស្សដែលទទួលផលប៉ះពាល់ដោយផ្ទាល់ និង ដោយប្រយោល និង ស្ថាប័នដែលទាក់ទងមានឱកាស ក្នុងការផ្តល់មតិកែលំអពីគំរោង។

## *៧.១ ការពិគ្រោះយោបល់សាធារណៈ*

Draft

ការពិគ្រោះយោបល់សាធារណៈពីរលើក ត្រូវបានធ្វើឡើងក្នុងកំឡុងពេលសិក្សា EIA ។ នៅក្នុងគោលបំណង នៃការប្រជុំការពិគ្រោះយោបល់លើកទី ១ គឺដើម្បីផ្សព្វផ្សាយអោយដឹងនូវពតិមានគំរោងទៅដល់សហគមន៍ និង ពិនិត្យឡើងវិញពីបញ្ហាបរិស្ថាន ដែលអាចកើតឡើងដោយសារសកម្មភាពរបស់គំរោង។ ការរៀបចំប្រជុំត្រូវបានធ្វើ ឡើងតាមរយៈអ្នកដឹកនាំសហគមន៍នៅថ្នាក់ឃុំ និង ថ្នាក់ភូមិ។ ខណៈដែលការពិគ្រោះយោបល់សាធារណៈលើកទីពីរ បានរៀបចំ បន្ទាប់ពីបញ្ចប់ការងារនៅទីវាល ហើយទទួលបានលទ្ធផលគ្រប់គ្រាន់ ដើម្បីបង្ហាញដល់អ្នកពាក់ព័ន្ធ។ តំណាងរបស់សហគមន៍ដែលប៉ះពាល់ដែលរួមមានមន្ទីរនៅថ្នាក់ខេត្ត ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និង ស្ថាប័ន ជាប់ទាក់ទងជាមួយគំរោងមកពីភ្នំពេញ។ សកម្មភាពលំអិត និង លទ្ធផលនៃការប្រជុំនៃការពិគ្រោះយោបល់ សាធារណៈ នីមួយៗ មានពណ៌នានៅក្នុងចំណងជើងតូចៗ និង កថាខ័ណ្ឌដូចខាងក្រោម។

### ៧.១.១ ការពិគ្រោះយោបល់សាធារណៈលើកទី ១

មានពីរជំហាននៅក្នុងការពិគ្រោះយោបល់សាធារណៈ លើកទីមួយត្រូវបានធ្វើឡើងនៅក្នុងសហគមន៍ដែល ប៉ះពាល់ដោយរួមបញ្ចូលទាំងឃុំមួយនៅក្នុងស្រុកកូនមុំ ខេត្តរតនគីរីផងដែរ។

**ការពិគ្រោះយោបល់សាធារណៈលើកទី ១ ជំហានទី ១:**

ការពិគ្រោះយោបល់សាធារណៈលើកទី ១ ត្រូវបានធ្វើឡើងនៅចន្លោះពីថ្ងៃទី ១-៤ កុម្ភៈ ២០០៨ នៅក្នុងឃុំ ចំនួន ៥ (ភ្លុក ក្បាលរមាស ស្រែអង្រ្កង ស្រែគរ និង តាឡាត់) ដែលជាកន្លែងដែលសកម្មភាពគំរោងនឹងប៉ះពាល់ ទៅលើធនធានធម្មជាតិ និង សង្គម។ សកម្មភាពស្តីពីការប្រជុំមានបង្ហាញនៅតារាងទី ៥៧។ កន្លែងប្រជុំ និង កាលបរិច្ឆេទនៃការពិគ្រោះយោបល់លើកទីមួយមានបង្ហាញនៅក្នុងតារាងទី ៥៨។ អ្នកភូមិដែលបានចូលរួមមានភាគ ច្រើនជាស្ត្រី។

Draft

**តារាងទី ៥៧:** សកម្មភាពលំអិតស្តីពីការពិគ្រោះយោបល់សាធារណៈលើកទី ១ និង ការស្ទង់មតិពីសេដ្ឋកិច្ចសង្គម

| លរ | សកម្មភាព | សំគាល់ |
|---|---|---|
| ១ | មុនការប្រជុំ | |
| ១.១ | រៀបចំអ្នកភូមិ/អ្នកចូលរួម ទីកន្លែងនៅក្នុងឃុំនិមួយៗ នៃស្រុកសេសាន ខេត្ត ស្ទឹងត្រែង និងស្រុកកូនមុំ ខេត្តរតនគីរី | ២ ឬ បី ថ្ងៃមុនដំណើរការប្រជុំ |
| ២ | ក្នុងដំណើរការប្រជុំ | |
| ២.១ | ការចុះឈ្មោះអ្នកចូលរួម | ៨:០០-៨:៣០ ព្រឹក |
| ២.២ | ការណែនាំរបស់ក្រុមសិក្សា គោលបំណងនៃការប្រជុំ និង ធ្វើការថតរូបមួយចំនួន | |
| ២.៣ | ការបង្ហាញពីពតិមានគំរោងៈ ការពន្យល់ និង ការចែកចាយឯកសារខ្លះៗ ដូចជា ផែនទីទីតាំងគំរោង ពតិមានសង្ខេបៗរបស់គំរោង (*) | ៨:៣០-៩:៣០ ព្រឹក |
| ២.៤ | សាកសួរអំពីទស្សនៈគំរោងពីអ្នកចូលរួម ការចូលរួមគំនិត យោបល់ និង សំណួរ។ ការសំរាកតូចមួយ ពិសារអាហារសំរន់ ដែលផ្តល់អោយនៅពេលជាមួយគ្នា | ៩:៣០-១១:០០ ព្រឹក |
| ២.៥ | ចំលើយខ្លះៗ និង កត់ត្រាសំណួរទាំងអស់ និង យោបល់ពីអ្នកចូលរួម | |
| ២.៦ | បិទការប្រជុំ ប្រមូលបញ្ជីអ្នកចូលរួម និង បញ្ជាក់ពីគ្រួសារដែលត្រូវសំភាសន៍ ដោយក្រុម KCC | ១១:០០-១១:១០ ព្រឹក |

**សំគាល់:** (*)ពតិមានគំរោងជាភាសាខ្មែរ (ឧបសម្ព័ន្ធទី ១) និង ប្រើប្រាស់ផែនទីនីវ៉ូអាងដែលបានស្នើពី PECC-១, ខែមករា, ២០០៨។

**តារាងទី ៥៨:** ទីកន្លែង និង កាលបរិច្ឆេទប្រជុំ នៃការពិគ្រោះយោបល់សាធារណៈលើកទីមួយ

| កាលបរិច្ឆេទ | ទីតាំង | | | | # អ្នកចូលរួម |
|---|---|---|---|---|---|
| | ខេត្ត | ស្រុក | ឃុំ | ទីតាំងជាក់លាក់ | |
| ១ កុម្ភៈ ២០០៨ ព្រឹក | ស្ទឹងត្រែង | សេសាន | ក្បាលរមាស | ក្នុងបរិវេណវត្ត ភូមិ ក្របីជ្រុំ | ១២៧ នាក់ |
| ១ កុម្ភៈ ២០០៨ រសៀល | ស្ទឹងត្រែង | សេសាន | ស្រែគរ | ក្នុងបរិវេណវត្តភូមិ ស្រែគរ | ១៣៦ នាក់ |
| ២ កុម្ភៈ ២០០៨ ព្រឹក | ស្ទឹងត្រែង | សេសាន | តាឡាត់ | នៅទល់មុខការិយាល័យ ឃុំតាឡាត់ | ៥៨ នាក់ |
| ២ កុម្ភៈ ២០០៨ រសៀល | រតនគីរី | កូនមុំ | ស្រែអង្រ្គង | ក្នុងបរិវេណវត្តភូមិ ស្រែអង្រ្គង | ១២០ នាក់ |

Draft

| | | | | | |
|---|---|---|---|---|---|
| ៤ កុម្ភៈ ២០០៨ ព្រឹក | ស្ទឹងត្រែង | សេសាន | ភ្លុក | ក្នុងបរិវេណវត្ត ភូមិ ភ្លុក | ១០៦ នាក់ |

បន្ទាប់ពីធ្វើការផ្សព្វផ្សាយពតិមានអំពីទំនប់ និង តំបន់ជំនន់របស់វារួចមក ការដាក់សំណួរថា " តើអ្នកគិតយ៉ាងដូចម្តេចដែរ ទៅលើគំរោងអភិវឌ្ឍន៏ដែលបានស្នើសុំ?" ត្រូវបានចោទសួរឡើង។ គំនិតផ្សេងៗដែលបានឆ្លើយទៅនឹងសំណួរមានបង្ហាញនៅក្នុងតារាងទី ៥៩។

**តារាងទី ៥៩:** គំនិតរបស់អ្នកចូលរួមការប្រជុំទៅពីគំរោងទំនប់ដែលបានស្នើ

| ឈ្មោះឃុំ | ទីតាំងតំបន់គំរោង | | គំនិត | | |
|---|---|---|---|---|---|
| | ខ្សែទឹកលើ | ខ្សែទឹកក្រោម | យល់ព្រម % | មិនព្រម % | គ្មានយោបល់ % |
| ក្បាលរមាស | x | | 0.0 | ១០០ | 0.0 |
| ស្រែគរ | x | | 0.0 | ១០០ | 0.0 |
| តាឡាត់ | x | | ៦.១ | ៩៣.៩ | 0.0 |
| ស្រែអង្រ្គង | x | | ១២.៣ | ៨៦.៩ | 0.៨ |
| ភ្លុក | | x | ៥៦.៨ | ៤២.១ | ១.១ |
| ***គំនិតជាមធ្យម*** | | | ***១៤.៥*** | ***៨៥.១*** | ***0.៤*** |

Draft

តាមពតិមានចាប់ផ្តើមដំបូង ដែលមាននៅដំណាក់កាលសិក្សាគំរោងថ្មីថ្មោងបំផុតនោះបង្ហាញថា ប្រហែល ៨៥%នៃប្រជាជនដែលបានពិគ្រោះយោបល់ មិនយល់ព្រមជាមួយគំរោងទេ ហើយប្រហែល ១៥%គាំទ្រគំរោង។

<u>**ការពិគ្រោះយោបល់សាធារណៈលើកទី ១ ជំហានទី ២:**</u>

ការប្រជុំត្រូវបានធ្វើឡើងដោយក្រុមសិក្សាការផ្លាស់ប្តូរទីលំនៅនៃ PECC-១ នៅក្នុងខែ មេសា ២០០៨។ អ្នកចូលរួមជាប្រជាជនរងផលប៉ះពាល់(APs) ដែលនឹងត្រូវប្តូរទីលំនៅទៅកន្លែងតាំងទីលំនៅថ្មី ដោយសារផលប៉ះពាល់ពីគំរោង។ ការប្រជុំត្រូវបានធ្វើឡើងបន្ទាប់ពីព្រឹត្តិការខ្លះៗដូចខាងក្រោម:

- គណៈប្រតិភូមួយត្រូវបានរៀបចំដោយម្ចាស់គំរោង ដើម្បីទស្សនកិច្ចធ្វើការទៅលើតំបន់តាំងទីលំនៅគំរូមួយចំនួននៅវៀតណាម។ អ្នកចូលរួម រួមមានអជ្ញាធរខេត្ត (តំណាងមន្ទីរក្នុងខេត្ត ស្រុកសេសាន...) និង ប្រធាន ឬ តំណាងឃុំ និង ភូមិដែលទទួលរងផលប៉ះពាល់។
- ការរៀបចំគ្រោងការនយោបាយទៅលើសំណង ការផ្តល់ប្រាក់អោយ និង ការតាំងទីលំនៅជាថ្មី សំរាប់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោម ២ (គ្រោងការងារ បានដាក់ជូនទៅអជ្ញាធរខេត្ត ដើម្បីសុំយោបល់នៅក្នុងខែកុម្ភៈ ២០០៨)។
- ចុះធ្វើការវាស្ទង់មតិជាមួយប្រជាជនដែលទទួលរងផលប៉ះពាល់ទាំងអស់ពីគ្រួសារមួយទៅគ្រួសារមួយ។ ក្នុងកំឡុងពេលធ្វើការវាស់ស្ទង់មតិនោះ អ្នកពិគ្រោះយោបល់បានបង្ហាញពីព្រំទ្រល់តំបន់ជន់លិច ការ

បាត់បង់ជាសក្តានុពលដែលបានកំណត់ដោយគំរោង និង បានពន្យល់ពីសំណង ការផ្តល់ប្រាក់ និង ការតាំងទីលំនៅថ្មីឡើងវិញផងដែរ ។

លទ្ធផលនៃការប្រជុំជំហានទី ២ សំរាប់ការពិគ្រោះយោបល់សាធារណៈលើកទី ១ នៅក្នុងសហគមន៍ដែលរងផលប៉ះពាល់ មានពណ៌នានៅក្នុងតារាងទី ៦០ ។

**តារាងទី ៦០:** គំនិតប្រជាជនដែលរងផលប៉ះពាល់ អំពីគំរោង:

| ឃុំ | សរុប (APs)* | មិនព្រម | | យល់ព្រម | |
|---|---|---|---|---|---|
| | | នាក់ | (%) | នាក់ | (%) |
| ភ្លុក | ៦៧ | គ្មានចំលើយ | | ១៤ | ២១ |
| ស្រែគរ | ២៧១ | ១២ | ១ | ២៥៧ | ៩៩ |
| ក្បាលរមាស | ៣៩៨ | ៤១ | ២ | ៣៥១ | ៩៨ |
| តាឡាត់ | ៥៨២ | ៨០ | ២ | ៤៩០ | ៩៨ |
| **សរុប** | **១៣១៨** | **១៣៣** | | **១១១២** | **៩៤** |

**សំគាល់:** * ចំនួនសរុបនៃប្រជាជនដែលរងផលប៉ះពាល់នៅក្នុងភូមិនិមួយៗដែលបានធ្វើការអង្កេត/សំភាសន៍

## ៧.១.២ ការពិគ្រោះយោបល់សាធារណៈលើកទីពីរ

ការប្រជុំពិគ្រោះយោបល់សាធារណៈលើកទីពីរ ត្រូវបានធ្វើឡើងដោយ KCC/PECC-១ នៅក្នុងខេត្តស្ទឹងត្រែង នៅថ្ងៃទី ៩ ឧសភា ឆ្នាំ ២០០៨ ដោយមានការចូលរួមពីអ្នករួមចំណែកដែលរងផលប៉ះពាល់ ដោយរាប់បញ្ចូលទាំងអ្នកតំណាងសហគមន៍ដែលរងផលប៉ះពាល់ គ្រប់មន្ទីរទាំងអស់នៅក្នុងខេត្ត អង្គការក្រៅរដ្ឋាភិបាល (CEPA, PSDD, MEDICAM, Oxfam Australia) ផ្នែកឯកជន (ក្រុមហ៊ុនដី និង ព្រៃសម្បទាន) ព្រមទាំងតំណាងនាយកដ្ឋាន EIA របស់ក្រសួងបរិស្ថាន និង នាយកដ្ឋានថាមពលរបស់ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល, សូមមើលបញ្ជីអ្នកចូលរួមនៅក្នុងឧបសម្ព័ន្ធទី ៥ ។

នៅក្នុងការពិគ្រោះយោបល់សាធារណៈលើកទី២ ត្រូវបានធ្វើឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់អភិបាល និង អភិបាលរងខេត្តស្ទឹងត្រែង។ អ្នកចូលរួមសរុបមានចំនួន ៤៥នាក់ ក្នុងនោះ ២៦ នាក់ជាមន្ត្រីរាជការ, ១០ នាក់ជាមេឃុំ មេភូមិ និង អនុប្រធានភូមិដែលមកពីសហគមន៍រងផលប៉ះពាល់ ៥ នាក់ ពីអង្គការក្រៅរដ្ឋាភិបាល និង ៤ នាក់ ពីផ្នែកឯកជន, សូមមើលបញ្ជីអ្នកចូលរួមនៅក្នុងឧបសម្ព័ន្ធទី ៥ ។

នៅក្នុងពេលប្រជុំ លទ្ធផលនៃការសិក្សាពីសមិទ្ធិលទ្ធភាពរបស់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោម ២ ទាំងទិដ្ឋភាពវិស្វកម្ម និង បរិស្ថាន ត្រូវបានផ្សព្វផ្សាយយ៉ាងច្បាស់ជាមួយរូបភាពដោយសំភារៈសំរាប់ធ្វើបទបង្ហាញ (ជា power point, words/excels, និង គំនូរ/ផែនទី) ការព្យាករណ៍ពីផលប៉ះពាល់នៅក្នុងការសាងសង់ និង

Draft

ការប្រតិបត្តិគំរោង ការបង្កើតវិធានការណ៍បន្ធូរបន្ថយសំរាប់ផលប៉ះពាល់អវិជ្ជមាននិមួយៗ។ លទ្ធផលនៃការប្រជុំត្រូវមានពណ៌នា នៅក្នុងតារាងទី ៦១។

**តារាងទី ៦១: លទ្ធផលនៃការពិគ្រោះយោបល់សាធារណៈលើកទី២**

| ឈ្មោះ | ឋានៈ និង អង្គការ | គំនិត, យោបល់ និង សំណួរ |
|---|---|---|
| លោក តេក វ៉ាន់ណារ៉ា | មន្ត្រីគំរោងសេប៉ា និង អង្គការ CEPA | បានសួរដល់វិស្វករវៀបចំប្លង់ (PECC-១) អោយពន្យល់ពីគំរោង តើមានកាប៉ាស៊ីតេដែលតំឡើងដល់ ៤២០ ឬ ៤៨០ មេកាវ៉ាត់?<br>សំណូមពរដល់ក្រុមសិក្សា ឬ វិស្វករវៀបចំប្លង់ដូចតទៅ:<br>- រៀបចំសំភារៈបទបង្ហាញជាភាសាខ្មែរ សំរាប់ការប្រជុំលើកក្រោយ ។<br>- វិស្វករវៀបចំប្លង់គួរកាត់បន្ថយកំរិតជំនន់នៅក្នុងអាង ព្រោះកាលណាកំពស់ទំនប់កាន់តែខ្ពស់ វានឹងបណ្តាលអោយមានផលប៉ះពាល់កាន់តែខ្ពស់ ដល់ធនធានសង្គម និង បរិស្ថាននៅក្នុងតំបន់ ។<br>- ធ្វើការពិភាក្សាអោយបានសមស្របជាមួយប្រជាជនសំរាប់ការសិក្សាពីការផ្លាស់ប្តូរទីលំនៅ ។<br>- ធ្វើគំរោងសកម្មភាពត្រឹមត្រូវសំរាប់ការរុះរើ/ការតាំងទីលំនៅរបស់ PAH/APs និង ការស្តារប្រាក់ចំណូលឡើងវិញ គួរតែត្រូវបានផ្តល់អោយ ។<br>- ក្រុមហ៊ុនគួរតែផ្តល់អោយនូវថាមពលអគ្គិសនីទៅដល់សហគមន៍នៅជុំវិញតំបន់គំរោងដោយតំលៃទាប និង មិនគិតថ្លៃចំពោះ PAH/APs ។ |
| លោក ឌី សុកហម | វិស្វករព្រៃឈើ, ខណ្ឌរដ្ឋបាលព្រៃឈើខេត្តស្ទឹងត្រែង | ខ្ញុំយល់ស្របជាមួយគំរោងអភិវឌ្ឍន៍, ប៉ុន្តែគំរោងនឹងជន់លិចតំបន់ព្រៃជាច្រើនពាន់ហិចតា និង ដីប្រើប្រាស់ជាច្រើនទៀតនៅក្នុងតំបន់ ។ យោងទៅតាមលទ្ធផលនៃការសិក្សាបង្ហាញថាជាមួយនឹងកំរិត FSL ៧៥ ម ដីប្រើប្រាស់ប្រហែល ៣០៥ គម² នៅក្នុងតំបន់ នឹងជន់លិចនៅក្នុងអាងស្តុកទឹក ហើយគេត្រូវការដីជាច្រើនពាន់ហិចតាទៀតដើម្បីតាំងទីលំនៅថ្មី ។<br>សំណូមពរទៅក្រុមហ៊ុនប្រតិបត្តិដើម្បីរាប់ពីសំណាងដីកសិកម្ម និង ដីផ្សេងទៀតរបស់គ្រួសាររងផលប៉ះពាល់ គួរតែស្មើគ្នាទៅនឹងដីដែលបាត់បង់ទៅ ។<br>ខ្ញុំចង់សួរទៅក្រុមសិក្សានូវសំណួរពីរ :<br>- គំរោង នឹងជន់លិច និង បំផ្លាញដី និង ព្រៃឈើទានមួយចំនួននៅក្នុងតំបន់ ដូច្នេះតើអ្នកណាជាអ្នកទទួលខុសត្រូវដោះស្រាយបញ្ហានេះ? |

Draft

| | | |
|---|---|---|
| | | - តំរូវការដីសំណងទៅដល់ PAH គឺមានច្រើនហិចតា តើធ្វើដូចម្តេច ដើម្បីដោះស្រាយបញ្ហានេះ? ពីព្រោះតំបន់ដី /ព្រៃភាគច្រើននៅក្នុង ស្រុកសេសានគឺនៅក្រោមសិទ្ធិប្រតិបត្តិការរបស់ក្រុមហ៊ុនដីសម្បទាន និង ព្រៃសម្បទាន, និង ព្រៃការពារ ឬ ព្រៃសហគមន៍។ ដូច្នេះតំបន់ តាំងទីលំនៅថ្មី និង ដីសំណង ដល់ដីដែលបាត់បង់ នឹងត្រូវទន្ទ្រានចូល ព្រៃការពារ/អភិរក្សនៅក្នុងតំបន់។ |
| លោក រីឆាត ឡយដ៏ Mr. Richard Lloyd | អ្នកពិគ្រោះយោបល់បរិស្ថាន | លោកឡយដ៏ គឺជាទីប្រឹក្សាផ្នែកបរិស្ថានដែលធ្លាប់ធ្វើការនៅឧទ្យានជាតិ វិរជ័យ និង ឧទ្យានសត្វព្រៃលំផាត់នៅក្នុងខេត្តរតនគិរី ដែលដឹងច្រើនអំពី ស្ថានភាពបរិស្ថាននៅតាមដងទន្លេសេសាន និង ស្រែពក។<br>ការសាងសង់ទំនប់នៃគំរោងសាងសង់រោងចក្រវារីអគ្គិសនីសេសានក្រោម ២ នឹងមានផលប៉ះពាល់គួរអោយកត់សំគាល់ទៅលើត្រីនៅទន្លេសេសាន និង ស្រែពកដោយសារការបង្អាក់នូវការផ្លាស់ទីរបស់ត្រីនៅក្នុងទន្លេ។ ផល ប៉ះពាល់ពីគំរោងទៅដល់ជីវភាពប្រជាជននៅខ្សែទឹកលើ នឹងកើតឡើង ផងដែរ ពីព្រោះពួកគេនឹងបាត់បង់អាហារប្រចាំថ្ងៃ (ត្រី)។<br>សំណួរចំបងពីរ ត្រូវបានសួរដល់ PECC-១ និង អ្នកពិគ្រោះយោបល់សិក្សា EIA (KCC) ដូចតទៅ:<br>- តើការសិក្សា EIA ចាត់ទុក ឬ កំណត់ ពីការបាត់បង់ជីវភាពសហគមន៍នៅ ខ្សែទឹកលើ តាមដងទន្លេសេសាន និង ស្រែពក ជាពិសេសនៅរតនគិរី ដែរឬទេ?<br>- តើការបាត់បង់ជីវភាពរបស់សហគមន៍ខ្សែទឹកលើនឹង ត្រូវបានទទួល សំណងយ៉ាងដូចម្តេច? |
| លោក ដាញ់ សេរី | អនុប្រធាននាយកដ្ឋាន វាយតំលៃផលប៉ះពាល់ បរិស្ថាននៃក្រសួង បរិស្ថាន | កន្លងមកក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជាបានទទួលឯកសារប្តឹង តវ៉ាពីវេទិកាអង្គការក្រៅរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលដទៃទៀត ដែលធ្វើការនៅក្នុងខេត្តរតនគិរី និង ខេត្តស្ទឹងត្រែង។ នៅក្នុងឯកសារទាំង នោះនិយាយអំពីផលប៉ះពាល់ទៅលើជីវិតមនុស្ស និង សត្វ និង ការបាត់បង់ ទ្រព្យសម្បត្តិ និង ផលប៉ះពាល់ទៅលើជីវភាពរបស់សហគមន៍នៅខ្សែទឹក ក្រោមនៃគំរោងវារីអគ្គិសនីនៅក្នុងទឹកដីវៀតណាម ដោយសារប្រតិបត្តិការ នៅទំនប់ខ្សែទឹកលើ (យ៉ាលី)។ |

Draft

| | | |
|---|---|---|
| | | សំណូមពរទៅក្រុមសិក្សានៃ PECC-១ និង KCC អោយធ្វើការស្រាវជ្រាវអោយបានត្រឹមត្រូវទៅលើធនធានបរិស្ថាន និង សង្គមដែលមានស្រាប់ រាប់បញ្ចូលនូវ ធនធានរូបសាស្ត្រ ជីវសាស្ត្រ និង ធនធានសង្គម នៅក្នុងតំបន់។ គាត់បានកត់សំគាល់ថា លទ្ធផលនៃការសិក្សាសង្គមហាក់ដូចជាលំអិត និង ត្រូវការដោះស្រាយ សំរាប់ PAH/APs ទាំងអស់ដែលបង្កដោយគំរោង។<br>សំណូមពរទៅក្រុមសិក្សារបស់ KCC អោយរៀបចំវិធានការណ៍បន្ធូរបន្ថយអោយបានត្រឹមត្រូវ ជាពិសេសសំរាប់ផលប៉ះពាល់ទៅលើជលផលនៅក្នុងទន្លេ។ ហើយផលប៉ះពាល់ទាំងអស់ទៅលើធនធានបរិស្ថានគួរតែ គិតគូរជាទឹកប្រាក់ ជាពិសេសការបាត់បង់ព្រៃ និង ត្រី។ |
| សំណួរទាំងអស់ត្រូវបានឆ្លើយដោយក្រុមសិក្សា វិស្វករ PECC-1 និង KCC។ ការសំរបសំរួលទៅនឹងគំនិត និងសំណូមពរមានប្រយោជន៍ពីអ្នកចូលរួមត្រូវបានយកមកពិចារណាសំរាប់ការរៀបចំគំរោង ការសាងសង់ និងប្រតិបត្តិការគំរោង។ | | |

លទ្ធផលចុងក្រោយនៃការប្រជុំ គឺដើម្បីទទួលយោបល់ និង អនុសាសន៍មានប្រយោជន៍ទាំងអស់ពីពាក់ព័ន្ធ ដើម្បីកែលំអបួងវិស្វកម្ម និង ដើម្បីបញ្ចូលវិធានការណ៍បន្ធូរបន្ថយបន្ថែមទៀត និងមធ្យោបាយពិនិត្យដាមដាននៅក្នុងការរៀបចំ EMP សំរាប់ការសិក្សា EIA។

Draft

## ៧.២ ការប្រជុំជាមួយអ្នកជាប់ទាក់ទងនឹងគំរោង

ស្ថាប័ន មន្ទីររដ្ឋាភិបាល អជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាល ដែលជាប់ទាក់ទងសំខាន់ៗ ត្រូវបានពិគ្រោះ ក្នុងពេលធ្វើការសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថានសំរាប់គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោម ២។ ក្រុមសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថាន បានជួបជាមួយអភិបាលស្រុក មេឃុំ មេភូមិ មន្ទីរកសិកម្ម, មន្ទីរសាធារណការ និង ដឹកជញ្ជូន មន្ទីរឧស្សាហាកម្ម រ៉ែ និង ថាមពល មន្ទីរបរិស្ថាន មន្ទីររៀបចំដែនដី នគររូបនីយកម្ម និង សំណង់ រដ្ឋបាលព្រៃឈើនៅក្នុងខេត្តស្ទឹងត្រែង អភិបាលខេត្តស្ទឹងត្រែង បណ្តាញការពារទន្លេ (3SPN) , WWF, និង NGO Forum។ បញ្ជីឈ្មោះអ្នកចូលរួមប្រជុំមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ៥។

លទ្ធផលនៃការប្រជុំពិគ្រោះយោបល់មួយអ្នកចូលរួមចំណែកមានពណ៌នានៅក្នុងតារាងទី ៦២។

តារាងទី ៦២: លទ្ធផលនៃការប្រជុំពិគ្រោះយោបល់

| កាលបរិច្ឆេទ | ឈ្មោះ | ឋានៈ និង ស្ថាប័ន | គំនិត, យោបល់ និង សំណួរ |
|---|---|---|---|
| ២២/១/០៨ | លោក ព្រំ | អភិបាលស្រុក | លោកនិយាយថានៅពាក់កណ្តាលខែមករា ២០០៨ ក្រុមសិក្សា |

| | | | |
|---|---|---|---|
| | សារ៉ែម | សេសាន | របស់ PECC-1 បានបញ្ជាក់ពីស្ថានភាពគំរោង និង សមាជិករបស់ក្រុមសិក្សា ។ គាត់បញ្ជាក់ថា ទាក់ទងទៅនឹងគំរោងសាងសង់ទំនប់នៅ ក្នុងស្រុកសេសាន នឹងបណ្តាលអោយមានហេតុប៉ះពាល់ទៅដល់ឃុំ ចំនួន ៤ គឺ តាឡាត់, ស្រែគរ, ភ្លុក និង ក្បាលរមាស ។ គាត់បន្ថែមថា គំរោងក៏បានប៉ះពាល់ទៅដល់ដី និងព្រៃសម្បទាននៅក្នុងស្រុកសេសានផងដែរ ។<br>លោកអភិបាលស្រុក សំណូមពរទៅក្រុមសិក្សាអោយធ្វើ សហប្រតិបត្តិការជាមួយអ្នកគ្រប់គ្រងក្នុងតំបន់ មុននឹងទៅទីវាល និង ធ្វើ ការសិក្សាអោយបានត្រឹមត្រូវ ។ គាត់បានណែនាំពីបុគ្គលិកជំនាញរបស់ស្រុក ដែលអាចជួយដល់ក្រុមសិក្សា ដើម្បីធ្វើការនៅទីវាល ដូចជា លោក បួរ សៃ (ប្រធានការិយាល័យគ្រប់គ្រងដីធ្លី) លោក ណាត ប៊ុនសំ (អនុប្រធានការិយាល័យបរិស្ថាន) និង លោក ស៊ន ប៊ុនធុំ (មន្ត្រីជលផល) ។ |
| ២៤/១/០៨ | លោក ឡា ហឿន | មេឃុំ, ឃុំក្បាលរមាស | ស្វាគមន៍ដល់ក្រុមសិក្សាដើម្បីធ្វើការអង្កេតនៅទីវាល ប៉ុន្តែតំណាងអោយប្រជាជននៅក្នុងឃុំក្បាលរមាស មានការបារម្ភជាមួយនឹង ការសាងសង់ទំនប់នៅលើទន្លេ ។សំណូមពរទៅក្រុមសិក្សារៀបប្លង់គំរោងដែលអាចជៀសវាងជំនន់ នៅកន្លែងតាំងទីលំនៅរបស់ភូមិ ។ ប៉ុន្តែបើសិនរាជរដ្ឋាភិបាលត្រូវការអនុវត្តនីគំរោងវារីអគ្គិសនីនៅក្នុងទន្លេសេសាន គាត់មិនជំទាស់ទេ ប៉ុន្តែសំណូមពរទៅក្រុមហ៊ុនអោយសងទៅលើអ្វីដែលអ្នកភូមិបានបាត់បង់ដោយសារគំរោង ។ |
| ២៥/១/០៨ | អ្នកស្រី ឯម ត្រាញ់ដើម Ms. Ame Tranhdem | អ្នកផ្តល់ដំបូន្មានផ្នែកពតិមាន និង ការតស៊ូមតិ បណ្តាញទន្លេ ៣S | កាលពីមុនយើងបារម្ភពីផលប៉ះពាល់របស់ទំនប់យ៉ាលីទៅលើសហ គមន៍នៅតាមដងទន្លេសេសាននៃប្រទេសកម្ពុជា ពីព្រោះគ្មានការសិក្សាលំអិត គ្មានសំណងទៅលើការប៉ះពាល់ទៅលើខ្សែទឹកក្រោម ជាពិសេសនៅក្នុងប្រទេសកម្ពុជា ពួកគាត់បានបញ្ជាក់ ។ កន្លងមក NGOs កម្ពុជាបានផ្សើរលទ្ធផល នៃការប៉ះពាល់នៅក្នុងប្រទេសកម្ពុជា ដោយទំនប់យ៉ាលីក្នុងពេលប្រតិបត្តិការឆ្នាំទី ១ និង ទី ២ ទៅអោយភាគីវៀតណាម ប៉ុន្តែមិនមានសញ្ញាណឆ្លើយតប |
| | លោក មាច មាន Mr. | អនុប្រធានសំរបសំរួលបណ្តាញ | |

Draft

| | | | |
|---|---|---|---|
| | Meach Mean | ទន្លេ ៣S | មកទល់បច្ចុប្បន្ននេះ ។<br>បច្ចុប្បន្ននេះយើងបារម្ភពីគំរោងសេសាន ១ និង សេសាន ២ បើសិន ជាគំរោងទាំងពីរត្រូវបានសាងសង់ និងដំណើរការ ពីព្រោះ ហេតុប៉ះពាល់បរិស្ថាន និង សង្គមស្រដៀងគ្នានឹងកើតឡើង ទៅលើ ខ្សែទឹកក្រោមទីតាំងទំនប់ ។ លោកបាននិយាយថា គំរោងសេសាន ២ នឹងប៉ះពាល់មិនត្រឹមតែសហគមន៍នៅខ្សែទឹកក្រោមប៉ុណ្ណោះទេ ប៉ុន្តែទៅដល់សហគមន៍នៅខ្សែទឹកលើផងដែរ ដោយសារលំនៅដ្ឋាន ក្នុងភូមិភាគច្រើនស្ថិតនៅជិតទន្លេ ។ គាត់ក៏បានជូនពត៌មានទៅ ក្រុមសិក្សាដែរថាមានបក្សីកំពុងរងគ្រោះ មួយពូជមានជំរកនៅ លើកោះក្នុងទន្លេសេសាន នៅចន្លោះខេត្ត ស្ទឹងត្រែងនិង រតនគីរី, យោងទៅតាមការស្រាវជ្រាវរបស់ WWF ឆ្នាំ ២០០៤-២០០៥ ។<br>លោកស្រីAme សួរសំណួរមួយទៅក្រុមសិក្សារបស់យើងថា តើមាន គោលនយោបាយរបស់ម្ចាស់គំរោងដើម្បីធានាអោយ បាននូវនិរន្តរ ភាពនៃការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ ដែរឬទេ? |
| ២៨/១/០៨ | លោក Andrew L. Maxwell | អ្នកគ្រប់គ្រង គំរោង ពូជព្រៃ រដូវប្រាំង, អង្គការ WWF | បច្ចុប្បន្ននេះ WWF កំពុងធ្វើការសិក្សាស្រាវជ្រាវទៅលើបក្សី ទឹកនៅតំបន់ស្រែស្រណុក ហើយរកឃើញ ដូចជាត្រយ៉ង ក្រៀល ស្វាពណិស ក្ងោកយក្ស ត្មាតត្នោត ត្នោតភ្លើង ។ គំរោងអាចជន់ លិចជំរកបក្សី នៅវាលខ្សាច់របស់ទន្លេ។ លោកមិនដឹងថាតើអ្វី ជាផលប៉ះពាល់ទេ ប៉ុន្តែលោកចង់ដឹងពីទំហំរបស់គំរោង និង ទីតាំងជាក់លាក់របស់ប្លង់គំរោង ។<br>បច្ចុប្បន្ននេះ WWF កំពុង ធ្វើការសិក្សាទៅលើសត្វព្រៃនៅ ខេត្តមណ្ឌលគីរី រួមបញ្ចូលតំបន់នៅក្បែរភូមិស្រែស្រណុក នៅច្រាំង ម្ខាងនៃទន្លេស្រែពក ។ ដូច្នេះ សំណើរតាំងទីលំនៅសារជាថ្មីសំរាប់ ភូមិស្រែស្រណុកដែលលើកឡើង ត្រូវលើកទៅដែនដីខេត្តមណ្ឌល គីរី អាចប៉ះពាល់ទៅដល់ជំរកសត្វ ព្រៃនៅក្នុងតំបន់នោះ ។ |
| ០១/២/០៨ | លោក ហឿន | ប្រធានសហ គមន៍ព្រៃឈើ, | នៅក្នុងឃុំស្រែគរមានព្រៃឈើសហគមន៍មួយឈ្មោះ ព្រៃអ្នក តាកាំកាន់ ដែលគ្រប់គ្រង និងប្រើប្រាស់ដោយសហគមន៍ |

Draft

| | | | |
|---|---|---|---|
| | ហេង | ឃុំស្រែគរ | ស្រែគរ។<br>ទាក់ទងទៅនឹងគំរោងសង់ទំនប់អាចប៉ះពាល់ទៅដល់សហគមន៍ព្រៃឈើនៅខាងក្រោយភូមិ ហើយទីលំនៅនៅភូមិស្រែគរអាចជន់លិច និង ខូចខាត។ គាត់គ្មានយោបល់ទៅលើការរៀបចំប្លង់គំរោងទេ ប៉ុន្តែគាត់សំណូមពរអោយក្រុមហ៊ុនអនុវត្តន៍បង់ប្រាក់ដល់ប្រជាជនដែលបាត់បង់ផ្ទះ, ដីស្រែ, និង ទ្រព្យសម្បត្តិដទៃទៀត។ |
| ០២/២/០៨ | លោក ហួល ប៊ុណ្ណាត | ជំទប់ទី ២, ឃុំតាឡាត់ | លោកបញ្ជាក់ថា នៅក្នុងឃុំតាឡាត់មានក្រុមជនជាតិភាគតិចចំនួន ៦ រស់នៅក្នុងឃុំដូចជា កាវ៉ែត, ទំពួន, ព្រៅ, ចារ៉ាយ, ឡាវ និងខ្មែរ។ បច្ចុប្បន្ននេះមានក្រុមហ៊ុនឯកជនមួយធ្វើការរុករករ៉ែត្បូងថ្ម ដែល កប់នៅផ្នែកខាងលើឃុំតាឡាត់ ចន្លោះព្រំដែនខេត្តរតនះគីរី និង ខេត្ត ស្ទឹងត្រែង។ គំរោង នឹងប៉ះពាល់ទៅលើគ្រួសារមួយចំនួនដែលរស់នៅតាមដងទន្លេ។<br>លោកមិនជំទាស់និងគំរោងទេ ប៉ុន្តែគំរោងត្រូវបង់ប្រាក់ដល់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគំរោង។ ប៉ុន្តែកំណប់រ៉ែត្បូងថ្មអាចនឹងមិនប៉ះពាល់ដោយសារគំរោងទេ ដោយសារទីតាំងកំណប់រ៉ែ ស្ថិតនៅឆ្ងាយពីតំបន់អាង។ |
| ២៤/៤/០៨ | លោក ទូច ចា និង លោក ណួយ សុភិរម្យ | ប្រធានមន្ទីរកសិកម្ម ខេត្តស្ទឹងត្រែង, ប្រធានការិយាល័យកសិកម្ម | មានសហគមន៍កសិករមួយឈ្មោះ "សាមគ្គីសាមគួយ" នៅស្រុកសេសានដែលមានសកម្មភាពចំបងលើដំណាំកសិកម្ម ស្រូវ និង ដំណាំដទៃទៀត។ សហគមន៍ខាងលើ ធ្វើការដោយមានការសហការគ្នា ចែកចាយធនធានលើការដាំស្រូវ និង ក្រេឌីត។ ប៉ុន្តែគ្មានប្រព័ន្ធធារាសាស្ត្រនៅក្នុងស្រុកសេសានទេ, ការដាំស្រូវ និង ដំណាំផ្សេងទៀត គឺពឹងផ្អែកលើទឹកភ្លៀង។ ប្រជាជនក្នុងតំបន់គំរោងប្រើទឹកទន្លេសំរាប់ការប្រើប្រាស់នៅក្នុងផ្ទះ និង សួនច្បារ ដំណាំ។<br>លោកនាយកបានបញ្ជាក់ថា ដីកសិកម្មនៅក្នុងស្រុកសេសានគឺ ៥២២០ ហត, ក្នុងនោះ ៤៩៥០ហត ជាស្រែវស្សា និង ២៧០ហត ជាដីកសិកម្មខ្ពង់រាប។ សេសានជាតំបន់ជង្រុកស្រូវចំបងមួយរបស់ខេត្តស្ទឹងត្រែង,គាត់បញ្ជាក់បន្ថែម។ ដីកសិកម្មតំបន់ខ្ពង់រាបរួមមាន (i) ការអនុវត្តន៍ការដាំដំណាំចល័តៈ ស្រូវចំការ, ពោត, ដំឡូងមី, |

Draft

| | | | |
|---|---|---|---|
| | | | ចេក ។ល ។ (ii) ការអនុវត្តនីការដាំដំណាំជាប់លាប់: ស្វាយ, ម្នាស់, ស្វាយចន្ទី, ចេក ។ល ។<br>គាត់ស្វាគមន៍គំរោងរោងចក្រវារីអគ្គិសនី សេសានក្រោម ២ ហើយ គាត់ធ្លាប់បានសហប្រតិបត្តិការជាមួយក្រុមសិក្សាផងដែរ ។ ប៉ុន្តែទាក់ទងនឹងគំរោង គាត់បារម្ភពីការបាត់បង់ដីកសិកម្មនៅក្នុងសហគមន៍ដែលទទួលផលប៉ះពាល់នៅក្នុងស្រុកសេសាន ។ គាត់បានដឹងថាគំរោង នឹងអនុវត្តន៍នៅក្នុងឆ្នាំ ២០០៩-២០១៤ ប៉ុន្តែមកទល់ពេលនេះ គាត់មិនទាន់ឃើញមានការរៀបចំសំរាប់ការតាំងទីលំនៅសារជាថ្មី ឬ សំណងទៅលើការបាត់បង់ដីនៅឡើយ ។ |
| ២៥/៤/០៨ | លោក ស គឹមណាត | ប្រធានមន្ទីរសាធារណៈការ និង ដឹកជញ្ជូន ខេត្តស្ទឹងត្រែង | បច្ចុប្បន្ននេះទូកភាគច្រើនបានឈប់ធ្វើដំណើរនៅតាមដងទន្លេ ហើយ ប៉ុន្តែទូកអ្នកស្រុក (ផ្ទុកតិចជាង ១តោន) នៅមានដំណើរការសំរាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយ តិចជាង ១០ ទូកក្នុងមួយថ្ងៃ ។ នេះជាលទ្ធផលនៃការធ្វើអោយប្រសើរឡើងនូវផ្លូវនៅក្នុងតំបន់ ។<br>គំរោងរោងចក្រវារីអគ្គិសនីសេសានក្រោម ២ នឹងជន់លិចស្ពានស្រែពក និង ផ្លូវជាតិលេខ ៧៨ ប្រវែង ២-៣គម ដោយសារការរៀបចំប្លង់គំរោង ប៉ុន្តែគំរោង នឹងផ្តល់ជាផលប្រយោជន៍ទៅអោយប្រជាជន មានថាមពលអគ្គិសនីសំរាប់ប្រើមានតំលៃថោកជាងសព្វថ្ងៃនេះ ។ គំរោងនឹងផ្តល់ផងដែរនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើននៅក្នុងតំបន់ តាំងទីលំនៅថ្មី ។ គាត់បញ្ជាក់ថា បច្ចុប្បន្ននេះក្រុមហ៊ុនចិនកំពុងបន្ត ការស្តារឡើងវិញផ្លូវជាតិលេខ ៧៨ និង ខ្សែផ្លូវថ្មីដើម្បីជៀសវាង តំបន់ជំនន់ដោយសារគំរោង រោងចក្រវារីអគ្គិសនីសេសានក្រោមទី ២ ។ ខ្សែផ្លូវថ្មីគឺបែកចេញពីខ្សែផ្លូវដែលមានស្រាប់នៅក្នុងភូមិច្រប់ ហើយភ្ជាប់ទៅខ្សែផ្លូវដែលមានស្រាប់នៅត្រពាំងក្រហម ។ លោកនាយកស្វាគមន៍ និង គាំទ្រគំរោង និងការណែនាំមួយចំនួន ទៅម្ចាស់គំរោងថា បន្ទប់ចំឡងនាវា (ship block) មិនទាន់មានការចាំបាច់ទេនៅពេលបច្ចុប្បន្ននេះ ប៉ុន្តែប្រហែលនៅពេលអនាគត ។ វាជាការប្រសើរ បើសិនជាគំរោងអាច |

Draft

| | | | |
|---|---|---|---|
| | | | ជួយសាងសង់ បន្ទប់ចំឡងនាវាបានកាន់តែប្រសើរ ។ |
| ២៥/៤/០៨ | លោក អោប សុវណ្ណ | អនុប្រធាន មន្ទីរ ឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តស្ទឹងត្រែង | ប្រភពទឹកសំរាប់ការផ្គត់ផ្គង់ទឹកនៅក្នុងខេត្តស្ទឹងត្រែង ត្រូវបានបូមមកពីទន្លេសេសាន ខ្សែទឹកក្រោមនៃតំបន់គំរោង ។ សព្វថ្ងៃនេះការផលិតប្រចាំថ្ងៃគឺ ១០០០ម$^{៣}$ ក្នុងមួយថ្ងៃ ផ្គត់ផ្គង់ ១៥ ម៉ោងក្នុងមួយថ្ងៃ ប៉ុន្តែតំរូវការគឺ ១៥០០ម$^{៣}$ -២០០០ម$^{៣}$ ក្នុងមួយថ្ងៃ ។ ថ្លៃទឹកគឺ ១៥០០រៀល/ម$^{៣}$ (០,៣៧$/ម$^{៣}$) ហើយតំបន់ដែលគ្របដណ្តប់មានប្រហែលតែ ៤០ %ប៉ុណ្ណោះ ។ ការសិក្សាមួយដែលឧបត្ថម្ភដោយ ADBបង្ហាញថា រោងចក្រថ្មីមួយសំរាប់ធ្វើប្រព្រឹត្តិកម្មទឹក និង ការពង្រីកបណ្តាញចែកចាយត្រូវមានជាចាំបាច់ ។ វាអាចសាងសង់ក្នុងរយៈពេល ៥ឆ្នាំ ។ គាត់បានកត់សំគាល់ថា កាលពី ៣ឆ្នាំមុន គុណភាពទឹកនៅក្នុងទន្លេសេសានមានការថយចុះ ល្អក់ខ្លាំងនៅរដូវវស្សា និង មានកំហាប់អាល់ហ្សេប្រផេះ និង បៃតងខ្ពស់ នៅរដូវប្រាំង ។ មានរោងចក្រផលិតទឹកកកតូចៗចំនួន៣ ។ រោងចក្រនិមួយៗប្រើ ប្រាស់ទឹកពី ១០០-១៥០ម$^{៣}$ ក្នុងខែ ។មិនមានឧស្សាហកម្មផ្សេងទៀត នៅក្នុងខេត្តស្ទឹងត្រែងទេ ។ ថ្លៃអគ្គីសនីគឺ ១២២០ រៀល/គីឡូវ៉ាត់ម៉ោង ហើយ មានត្រឹមតែ ៧០ % នៅតាមតំបន់ទីក្រុងតែប៉ុណ្ណោះ ។ លោកប្រធានមន្ទីរឧស្សាហកម្មរ៉ែ និង ថាមពល បានផ្តល់នូវការ សំរបសំរួលជាមួយក្រុមសិក្សារបស់ PECC-1 សំរាប់ការសិក្សា គំរោង ។<br>តំណាងអោយប្រធានមន្ទីរ និង ខ្លួនគាត់ផ្ទាល់សូមស្វាគមន៍ចំពោះគំរោងរោងចក្រវារីអគ្គីសនីសេសានក្រោមទី២ ហើយស្នើអោយក្រុមហ៊ុនអនុវត្តអោយបានឆាប់បើអាចធ្វើទៅបាន ។ វានឹងធ្វើអោយតំលៃបង់ចំណាយទាបសំរាប់ការប្រើប្រាស់ទឹក ប្រសិនបើតំលៃអគ្គីសនីដែលបានពីការសាងសង់ថោកជាងតំលៃសព្វថ្ងៃ ។ មន្ទីរឧស្សាហកម្មរ៉ែ និង ថាមពល សូមស្វាគមន៍គំរោងអភិវឌ្ឍន៍អគ្គីសនី និង សូមអោយមានការសាងសង់លឿនតាមដែលអាចធ្វើទៅបាន ។ វាអាចធ្វើអោយតំលៃទឹកស្អាតចុះថោក ដោយសារអគ្គិសនីមានតំលៃទាប ។ |

Draft

| | | | |
|---|---|---|---|
| ២៥ /៤ /០៨ | លោក អេង ភីរុង | ប្រធានមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង | តំបន់គំរោងគឺនៅក្រៅតំបន់អភិរក្សបរិស្ថានដូចជា វីរជ័យ និង រាមសរ ។ ប៉ុន្តែមានសត្វព្រៃ និង ព្រៃជាច្រើននៅផ្នែកខាងលើនៃ ឃុំតាឡាត់ គាត់បញ្ជាក់ ។ ចំនួនសត្វព្រៃបានកើនឡើងបន្ទាប់ពីការ ដាក់អោយប្រើប្រាស់ប្រកាស លេខ. ១៥៦៣ ប្រក.បស ។ នៅទន្លេសេកុងមានពូជបក្សីកំរ " white shouldered Ibis *(Pseudibis davisoni* "ជាង ១០០ក្បាល ត្រូវបានរាយការណ៍ ដោយអង្គការបក្សីព្រៃអន្តរជាតិ និង មន្ទីរបរិស្ថាន (២០០៣-បច្ចុប្បន្ន) ។ ត្រីពិសេស/មានតំលៃនៅក្នុងតំបន់ដែលមានឈ្មោះថា "ត្រីប៉ាសេអ៊ី" ( *Mekongina erythrospila)* មានច្រើននៅក្នុង ទន្លេសេសាននៅចន្លោះចំនុចបំបែកទៅទន្លេមេគង្គ និង ភូមិខ្សាច់ថ្មី (ឃុំតាឡាត់) ។ មានការបារម្ភថាត្រីភាគច្រើននឹងត្រូវបំផ្លាញ នៅពេលដែលទំនប់ត្រូវបានសាងសង់ ។<br>ក្រៅពីការព្រួយបារម្ភពីការផ្លាស់ប្តូរបបធារទឹកយ៉ាងខ្លាំងនៅខ្សែ ទឹកក្រោមរបស់គំរោង ដោយសារបច្ចុប្បន្ន ទន្លេសេសាននៅក្នុង ប្រទេសកម្ពុជា មានការប្រែប្រួលធារទឹកយ៉ាងខ្លាំង ដោយសារ ការប្រតិបត្តិការទំនប់យ៉ាលី ។ ជារួម គំរោងនឹងមានផលប៉ះពាល់ គួរអោយកត់សំគាល់ទៅលើធនធានធម្មជាតិ និង ការរស់នៅរបស់ អ្នកភូមិនៅតាមដងទន្លេទាំងពីរ សេសាន និង ស្រែពក ។ ប៉ុន្តែ គំរោង និង ផ្តល់ប្រយោជន៍ជាច្រើន ផងដែរ ។<br>សំណូមពរទៅវិស្វកររៀបចំប្លង់ និង ក្រុមសិក្សាដូចខាង ក្រោម:<br>- គួរកាត់បន្ថយផលប៉ះពាល់ទៅលើធនធានសង្គម និង បរិស្ថាន នៅក្នុងតំបន់អោយបានច្រើនតាមដែលអាចធ្វើទៅបាន ។<br>- បង្ហូរទឹកអោយបានគ្រប់គ្រាន់ទៅខ្សែទឹកក្រោមក្នុងករណី កំឡុងពេលសំរាកដំណើរការ ។ |
| ២៥ /៤ /០៨ | លោក ហ៊ី ចន្ថា | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម | លោកបានរៀបរាប់ពីការងារមួយចំនួនដែលទាក់ទងទៅនឹងការ គ្រប់គ្រងដីធ្លី ។ ឧទាហរណ៍ ដីសម្បទានសេដ្ឋកិច្ចគ្រប់គ្រងដោយ រដ្ឋបាលព្រៃឈើ និងដីសម្បទានសង្គមកិច្ច រៀបចំ/អភិវឌ្ឍន៍ដោយ |

Draft

| | | | |
|---|---|---|---|
| | | និង សំណង់ ខេត្តស្ទឹងត្រែង | មន្ទីររបស់លោក និង គ្រប់គ្រងដោយអភិបាល ។ ពុំមានដីសម្បទានសង្គមកិច្ចបានធ្វើការអភិវឌ្ឍន៍នៅក្នុងស្រុកសេសាននៅឡើយទេមកដល់សព្វថ្ងៃនេះ (ឧសភា ២០០៨) ។ ប្រជាជនភាគច្រើននៅក្នុងស្រុកសេសានមិនមានឯកសារ ឬ ក្រដាសស្នាមកម្មសិទ្ធិដីធ្លីទេ ។ ទាក់ទងទៅនឹងផលប៉ះពាល់របស់គំរោងគាត់បានបញ្ជាក់ថា ប្រសិនបើការផ្លាស់ប្តូរទីលំនៅនឹងកើតឡើងដោយសារការអនុវត្តន៍គំរោង ក្រុមហ៊ុនប្រតិបត្តិគួរចេញសងដល់គ្រួសារ ឬ ប្រជាជនដែលរង ផលប៉ះពាល់ ។<br>សំណូមពរដល់ក្រុមហ៊ុនវៀតណាម:<br>- រៀបចំផែនការគ្រោងផ្លូវអោយបានច្បាស់លាស់ ។<br>- ធ្វើការអភិវឌ្ឍន៍ទីកន្លែងតាំងទីលំនៅថ្មី ។<br>លោកបានបញ្ជាក់ពីគំនិតរបស់គាត់ថា ១០០% គាំទ្រដល់គំរោងពី ព្រោះថាផលប៉ះពាល់នៃរោងចក្រវារីអគ្គិសនីមានតិចតួចហើយផល កំរៃមានច្រើន ។ថាមពលចេញពីរោងចក្រវារីអគ្គីសនី នឹងមានតំលៃ ថោកជាងថាមពលដែលបានពីម៉ាស៊ីនភ្លើងដើរដោយប្រេងឥន្ធនះ ។ |
| ២៦/៤/០៨ | លោក ជាម យូ ដុង | អនុប្រធានខណ្ឌរដ្ឋបាលព្រៃឈើ, ខេត្តស្ទឹងត្រែង | លោកបានបង្ហាញពីផែនទីដី និង ព្រៃសម្បទាននៅក្នុងខេត្តស្ទឹងត្រែង ទៅដល់ក្រុមសិក្សា EIA ។ លោកក៏បានបង្ហាញដែរពីព្រៃឈើមូលដ្ឋាននៅភូមិអូរខ្សាច់ ព្រៃ សហគមន៍នៅក្នុងភូមិស្រែគរ ព្រៃនៅតាមទីជំរាលនៅក្នុងភូមិច្រប់ និង តំបន់បំរុងសំរាប់ព្រៃសហគមន៍នៅក្នុងភុមិស្រែស្រណុក ។<br>យោងទៅតាមគ្រោងរបស់គំរោង រោងចក្រវារីអគ្គិនីសេសានក្រោម ២ នឹងមានផលប៉ះពាល់ទៅដល់ដីសម្បទាន ៥ និង ព្រៃសម្បទាន ១ ដែលមានឈ្មោះដូចតទៅ: សុភ័គ្រ នីកា ហ្វ្រេនលែន ភូម៉ាឌី ស៊ីវ ហ៊្វិច សល់ សុភា គ្រេត និង ភាពីម៉ិច គាត់បញ្ជាក់ ។<br>លោកមិនមានការជំទាស់ទៅនឹងការអភិវឌ្ឍន៍គំរោងទៅលើទន្លេសេសានទេ ប៉ុន្តែសំណូមពរទៅក្រុមហ៊ុនប្រតិបត្តិអោយធ្វើការពិចារណាទៅលើផលប៉ះពាល់ទៅលើដី និង ព្រៃនៅក្នុងតំបន់ ។ |

Draft

| | | | |
|---|---|---|---|
| | | | សំណងសមស្របគួរធ្វើឡើងដោយម្ចាស់គំរោង ដល់ក្រុមហ៊ុនដីសម្បទាន និង គ្រួសារដែលរងផលប៉ះពាល់ ។ |
| ០៨/ ៥/ ០៨ | ឯកឧត្តម ឡូយ សុផាត | អភិបាលខេត្ត ស្ទឹងត្រែង | ក្រុមហ៊ុនអនុវត្តគំរោងបានរាយការណ៍ពីលទ្ធផលដំណើរការនៃការសិក្សាគំរោង និង បង្កើតដំណោះស្រាយដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងចំពោះ PAH និង APs ។ ក្រុមសិក្សាបានបង្ហាញថា តំបន់តាំងទីលំនៅត្រូវបានជ្រើសរើសយោងទៅតាមការណែនាំរបស់អភិបាលខេត្ត និង សំណូមពរពីសហគមន៍ ហើយចំពោះតំបន់តាំងទីលំនៅ ក្រុមហ៊ុននឹង អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាំងអស់ដូចជា ផ្លូវថ្នល់ សាលារៀន វត្ត ការផ្គត់ផ្គង់ទឹក ។ល។ ក្រុមសិក្សាក៏បានបញ្ជូនរបាយការណ៍ស្តីពីសំណងទៅដល់ប្រជាជនដែលប៉ះពាល់ ដល់អភិបាលខេត្ត ក៏ដូចជាដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលផងដែរ ។ ក្រុមហ៊ុននឹងបង្កើតគណៈកម្មការដំណោះស្រាយថ្នាក់ខេត្ត និង ក្រសួងដែលជាប់ទាក់ទង ។<br>ទាក់ទងទៅនឹងលទ្ធផលនៃការសិក្សាដែលបានធ្វើឡើងដោយ PECC-1 និង KCC consultants ឯកឧត្តមអភិបាលខេត្តបញ្ជាក់ថាគំរោង នឹងប៉ះពាល់ទៅដល់ធនធានបរិស្ថាន និង សង្គម ហើយចាំបាច់ត្រូវកំណត់ពីផលកំរៃទៅលើចំណូលជាតិ. ដូច្នេះគំរោងត្រូវសងដល់ផលប៉ះពាល់ទាំងអស់ដែលបណ្តាលមកពីគំរោង ។ គាត់បានឮពីប្រជាជនដែលទទួលផលប៉ះពាល់ សំណូមពរអោយក្រុមហ៊ុនរៀបចំប្លង់ កាត់បន្ថយកំរិតទឹកជំនន់នៅត្រឹម ៦០ ម (និវ៉ូមធ្យមធៀបទឹកសមុទ្រ) ។ នៅក្នុងភូមិភ្លុកមានទឹកធ្លាដែលមានសក្តានុពលសំរាប់ការអភិវឌ្ឍន៍ទេសចរណ៍ លោកបានបន្ថែម ។<br>ទោះជាយ៉ាងណា យោងទៅតាមការសិក្សាពីមុនស្តីពីសុខភាពបានបង្ហាញថា ប្រជាជនមួយចំនួននៅក្នុងឃុំភ្លុកកើតជំងឺ Schistosomiasis ដែល បណ្តាលមកពី Schistosoma នៅក្នុងទន្លេសេសាន ។ ឯកឧត្តម បានផ្តល់អនុសាសន៍ និង សំណូមពរទៅក្រុមហ៊ុនដូចខាងក្រោម:<br>- ទីតាំងទំនប់ គួរសង់ឡើងអោយបានឆ្ងាយល្អមពីទឹកធ្លា |

Draft

| | | | |
|---|---|---|---|
| | | | នៅក្នុងភូមិភ្លុក ។<br>- កន្លែងចែកចាយចេញពីអាគារផលិតថាមពល គួរតំឡើងអោយបានឆ្ងាយល្មមពីសហគមន៍ភ្លុក ។<br>- សាងសង់ស្ពានមានគុណភាពល្អ ឆ្លងកាត់ទន្លេសេសាននៅក្នុងឃុំភ្លុក ដើម្បីឆ្លងទៅកន្លែងតាំងទីលំនៅថ្មីដែលបានស្នើសុំ នៅត្រើយខាងឆ្វេងនៃទន្លេ និង ភ្ជាប់ទៅផ្លូវជាតិលេខ ៧៨ ខាងលើខ្សែទឹកនៃទីតាំងអាង ។<br>- ផ្តល់សំណងត្រឹមត្រូវទៅដល់ PAH/APs ។<br>- ធានាអោយបានពីជីវភាពរស់នៅរបស់ប្រជាជនដែលរងផលប៉ះពាល់ ថានឹងបានប្រសើឡើង ។<br>លោក អភិបាលខេត្តបានលើកជាសំណួរទៅដល់ PECC-1 ថា:<br>- តើត្រូវដោះស្រាយផលប៉ះពាល់លើដីសម្បទានដោយរបៀបណា?<br>*ចំលើយទៅនឹងសំណួរខាងលើ អជ្ញាធរអគ្គិសនី និង MIME នឹង ធ្វើសំណូមពរទៅ MAFF , និង CDC និង រាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហានេះ ។* |

Draft

Draft